សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣១៦/១០-៥-២០០៦
សាលដីកា
លេខ ៦២ "ញ"/២២-១០-២០០៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍

បានបើកការជំនុំជម្រះជាសាធារណៈ នៅសាលាឧទ្ធរណ៍ ថ្ងៃទីម្ភៃពីរ ខែតុលា ឆ្នាំពីរពាន់ប្រាំបី

**សមាសភាពក្រុមប្រឹក្សា**

១-លោក [redacted] ជាប្រធាន
២-លោក [redacted] ចៅក្រម
៣-លោក [redacted] ចៅក្រម

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៦ ចុះថ្ងៃទី ១០-៥-២០០៦ ។

ជនជាប់ចោទឈ្មោះ [redacted] ណាង ហៅ [redacted] ណាង ភេទប្រុស អាយុ ៤៥ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ [redacted] ស្រុកពារាំង ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៣ នាក់ ទោសពីមុន គ្មាន ចាប់ខ្លួននៅថ្ងៃទី ៥-១០-២០០៥ ឃុំខ្លួននៅថ្ងៃទី ០៦-១០-២០០៥ នៅក្នុងពន្ធនាគារខេត្តព្រៃវែង ។

**ត្រូវចោទពីបទ :** ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃក្រឡាញ់តូច ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី ០៤-១០-២០០៥ តាមមាត្រា ៣ នៃ ច្បាប់ស្តីពីទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គីមហុង** ភេទ ស្រី អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ មានទីលំនៅ ភូមិព្រៃក្រឡាញ់តូច ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង ត្រូវជាប្អូនថ្លៃ ជនរងគ្រោះឈ្មោះ [redacted] **សុភី** ភេទស្រី អាយុ ៥៦ ឆ្នាំ ។

ឈ្មោះ [redacted] **គីមហុង** ដូរអាស័យដ្ឋាន សព្វថ្ងៃនៅផ្ទះលេខ ៧២ ផ្លូវលេខ ២៥ ក្រុមទី៥ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-មេធាវីតំណាងអាណត្តិ [redacted] សុផល ។

៩៩

## រឿងហេតុដូចតទៅ :

-តាមពាក្យបណ្ដឹងចុះថ្ងៃទី ១១-១០-២០០៥ របស់ [redacted] គឹមហុង ថា កាលពីថ្ងៃទី ០៤-១០-២០០៥ ឈ្មោះ [redacted] ណាង ហៅ [redacted] ណាង បានចកសុំទឹកតែនៅផ្ទះ [redacted] សុភី ជាជនរងគ្រោះ ប្រហែលម៉ោង ១០ យប់ ផឹករួច [redacted] ណាង ហៅ [redacted] ណាង ពន្លត់ចង្កៀង ហើយចាប់ឈ្មោះ [redacted] សុភី រំលោភ តែត្រូវ [redacted] សុភី ស្រែកថ្អើលឆោឡោ [redacted] ណាង ហៅ [redacted] ណាង ក៏ឈប់ចាប់ ដើរចូលផ្ទះបាយយកកាំបិតមកចាប់ [redacted] សុភី ម្ដងទៀតបានសំរេច រួចកាប់ [redacted] សុភី ជាច្រើនកាំបិត ដូចជា ក្បាល ១០កាំបិត, ក្រោមត្រចៀកស្ដាំ ១៧ ស.ម ជំរៅ ៣ ស.ម, ស្មាស្ដាំ ១២ ស.ម ជំរៅ ១ ស.ម ។ ផ្នែកក្បាល ២ កន្លែង ប្រវែង ៤ ស.ម ជំរៅ ១ ស.ម, ផ្នែកខ្នង ៤កន្លែង ប្រវែង ៤ ស.ម ជំរៅ ២ ស.ម, កដៃឆ្វេង ៤ ស.ម ជំរៅ ដាច់ឆ្អឹង, កដៃស្ដាំ ៨ ស.ម ជំរៅ ១ ស.ម ។ខ្លួនពុំបានឃើញផ្ទាល់ភ្នែកទេ ។

សំណូមពរ : ផ្ដន្ទាទោសជនល្មើសតាមច្បាប់, ទាមទារជម្ងឺចិត្ត ថ្លៃធ្វើបុណ្យសព និងសំរាប់ចិញ្ចឹមកូនមិនទាន់មាននីតិភាព ១០០.០០០.០០០៛(មួយរយលានរៀល) ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០២"គ" ចុះថ្ងៃទី ០៥-០១-២០០៦ របស់តុលាការខេត្តព្រៃវែង សំរេច :

១-ផ្ដន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ [redacted] ណាង ហៅ [redacted] ណាង ភេទប្រុស អាយុ ៤៥ ឆ្នាំ ជាតិខ្មែរ កំណត់ ១៨ ឆ្នាំ (ដប់ប្រាំបីឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ០៦-១០-២០០៥ ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រៃក្រឡាញ់តូច ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី ០៤-១០-២០០៥ តាមមាត្រា ៣ នៃ ច្បាប់ស្ដីពីទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់អោយឈ្មោះ [redacted] ណាង ហៅ [redacted] ណាង ចេញសំណងជម្ងឺចិត្តជាប្រាក់រៀលអោយទៅឈ្មោះ [redacted] គឹមហុង ជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៨.០០០.០០០ រៀល (ប្រាំបីលានរៀល) ទាមទារលើសពីនេះបដិសេធចោល ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ ។ ក្នុងករណីពុំមានប្រាក់សងធនទណ្ឌគ្រប់ចំនួនទេ ត្រូវដាក់គុកបង្ខំលើរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ តាមមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបរាងកាយ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៨ ក្រ. ចុះថ្ងៃទី ០៨-០២-១៩៩២ ។

៣-វត្ថុតាង កាំបិតប៉ុងតោ ១ផ្លែស ដងឈើ ទទឹង ៧ស.ម បណ្ដោយ ១៨ ស.ម ដងឈើប្រវែង ១៤ ស.ម ត្រូវរឹបអូស និងបំផ្លាញចោល ។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ [redacted] ណាង ហៅ [redacted] ណាង ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមហុង ចំពោះមុខមេធាវីឈ្មោះ [redacted] សុវណ្ណាលី ការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] ណាង និងចំពោះមុខមេធាវី [redacted] ស៊ាម ការពារសិទ្ធិអោយជនរងគ្រោះឈ្មោះ [redacted] សុភី បើភាគីណាមួយមិនសុខចិត្តនឹង

សេចក្តីសំរេចនៃសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ឈ្មោះ [redacted]ណាង ហៅ[redacted]ណាង ចុះថ្ងៃទី ០១-៣-២០០៦ ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី.........................របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គីមហុង (ចូល)
- ជនល្មើសឈ្មោះ [redacted]ណាង ហៅ [redacted]ណាង (អវត្តមាន)
- មេធាវីជនជាប់ចោទ[redacted]អូន (ចូល)

## ក្រុមប្រឹក្សាសង្ខេបរឿងហេតុ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គីមហុង ឆ្លើយថា : ខ្លួនពុំបានដឹងហេតុការណ៍អ្វីទេ ។

## មហាអយ្យការសន្និដ្ឋាន

ជនល្មើសសារភាពអស់ហើយនូវអំពើល្មើសរបស់ខ្លួន ដូច្នេះសុំតំកល់សាលក្រមតុលាការខេត្តព្រៃវែងដដែល ។

-មេធាវីការពារជនល្មើសធ្វើសេចក្តីសន្និដ្ឋាន : ដោយជនជាប់ចោទសារភាព សុំអោយក្រុមប្រឹក្សាបន្ធូរបន្ថយទោស ។

[redacted]គីមហុង : ខ្លួនសំណូមពរសុំតំកល់សាលក្រមតុលាការខេត្តព្រៃវែង ។

## ក្រុមប្រឹក្សាជំនុំជម្រះថយពិភាក្សា និងប្រកាសសាលដីកា

-យល់ឃើញថា : បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០១-០៣-២០០៦ របស់ឈ្មោះ [redacted] ណាង ហៅ [redacted] ណាង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា : ជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធីគឺថា : នៅថ្ងៃទី ០៤-១០-២០០៥ ខ្លួនបានរំលោភទៅលើជនរងគ្រោះ រួចកាប់ជាច្រើនកាំបិតទៅលើជនរងគ្រោះ បណ្តាលអោយជនរងគ្រោះស្លាប់ ដែលជាអំពើឃាតកម្មគិតទុកជាមុន ។

-យល់ឃើញថា : រឿងក្តីនេះត្រូវបានតុលាការខេត្តព្រៃវែងធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើការលើកឡើងនោះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

-យល់ឃើញថា : សាលក្រមព្រហ្មទណ្ឌលេខ ០២"គ" ចុះថ្ងៃទី ០៥-០១-២០០៦ របស់តុលាការខេត្តព្រៃវែង សំរេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីតំកល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ណាង ហៅ [redacted]ណាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ០២ "គ" ចុះថ្ងៃទី០៥-០១-២០០៦ របស់តុលាការខេត្តព្រៃវែង ទុកជាបានការដដែល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted]ណាង ហៅ [redacted] ណាង ជាបន្តទៀត ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២២-១០-២០០៨ ចំពោះមុខដើមបណ្តឹង និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់អំណោច និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]